សាធារណរដ្ឋប្រជាមានិតកម្ពុជា ជ.ទី

ាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

…: ១២១ ទ.ប.ក

ភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៨៨

# របាយការណ៍

## ស្តីពីសភាពការណ៍ការងារ ១០ ឆ្នាំ និងទិសដៅឆ្នាំ ១៩៨៩ របស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

ថ្ងៃទី ៧ មករា ឆ្នាំ ១៩៧៩ បានបង្កើតឡើងនូវសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបាននាំមកនូវការរស់ឡើងវិញ រួចផុតពីរណ្តៅមរណៈនៃរបបប្រល័យពូជសាសន៍ និង ក្តីសង្ឃឹមរបស់ប្រជាជនកម្ពុជាយើង ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សប្រជាជនបដិវត្តកម្ពុជា គួបផ្សំនឹងការជួយឧបត្ថម្ភដ៏មានប្រសិទ្ធភាព និងទាន់ពេលវេលាពីកងទ័ពស្ម័គ្រចិត្ត និងជំនាញការវៀតណាម ព្រមទាំងការជួយឧបត្ថម្ភពីបណ្តាប្រទេសសង្គមនិយមជាបងប្អូន និងបណ្តាប្រទេសជឿនលឿនពីអង្គការអន្តរជាតិនានា ប្រជាជនទាំងមូល កងទ័ពទាំងមូល ក្នុងស្មារតីស្នេហាជាតិមាតុភូមិ បានប្តូរផ្តាច់អនុវត្តរាល់គោលការណ៍ គោលនយោបាយ សេចក្តីសំរេចចិត្តនៃមហាសន្និបាតបក្សលើកទី ៣-៤ និង ទី ៥ បានដាក់ចុះ ។

ការខិតខំប្រឹងប្រែងអនុវត្តរាល់ភារកិច្ចខាងលើ ធ្វើអោយសាធារណរដ្ឋប្រជាមានិតកម្ពុជាពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរឹងមាំ ។ ជីវភាពរបស់ប្រជាជនបានត្រូវលើកកំពស់ ហើយឧបាយកលរបស់ខ្មាំងសត្រូវត្រូវបរាជ័យបន្តបន្ទាប់ និងឈានទៅរសាយសាបសូន្យ ។ ឆ្នាំ ១៩៨៨ នេះជាឆ្នាំគន្លឹះ និងជាឆ្នាំទី ៣ មានអត្ថន័យបំផុតក្នុងការអនុវត្តកម្មវិធីសេដ្ឋកិច្ច ៥ ឆ្នាំលើកទី ១របស់យើង ដែលមហាសន្និបាតបក្សលើកទី ៥ បានដាក់ចុះ ។ បក្ខជន កម្មាភិបាល បុគ្គលិក កម្មករ និង ប្រជាជន យើងពុះពារការលំបាកស្មុគស្មាញគ្រប់បែបយ៉ាង ដើម្បីអនុវត្តអោយបានសំរេចជោគជ័យនូវភារកិច្ចការពារ និងកសាងមាតុភូមិរបស់ខ្លួន ។ គោលនយោបាយបង្រួបបង្រួមជាតិក្នុងសុឆន្ទៈរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានមតិជាតិ និងអន្តរជាតិអបអរសាទរ និងគាំទ្រយ៉ាងក្លៀវក្លា ដោយឡែកកម្មាភិបាល បុគ្គលិក កម្មករ នៃខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក៏បានខិតខំយកអស់ស្មារតី និងសមត្ថភាពបំពេញភារកិច្ចតាមតួនាទីជាសេនាធិការជូនក្រុមប្រឹក្សារដ្ឋមន្ត្រី បានសំរេចជោគជ័យជាបន្តបន្ទាប់គួរកត់សំគាល់ ។

## ភាគទី ១

### សភាពការណ៍នៃការអនុវត្តភារកិច្ចការងារ ១០ ឆ្នាំ លើកទី ១ របស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

**I- រចនាសម្ព័ន្ធចាត់តាំងរបស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី :**

តាមសេចក្តីសំរេចលេខ ៤៩ កប. ចុះថ្ងៃទី ២៧-១២-១៩៧៩ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត មន្ទីរបូកសរុបរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត ឬ មន្ទីររដ្ឋ ត្រូវបង្កើតឡើងឋិតក្រោមការដឹកនាំផ្ទាល់របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា មានតួនាទីបំរើ[illegible]ភាពរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត បានការជួយឧបត្ថម្ភពីជំនាញការវៀតណាម អនុវត្តបណ្តាកម្មវិធីរបស់មន្ទីរសរុបក្រុមប្រឹក្សាប្រជាជនបដិវត្ត ។ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៨០ ផ្អែកតាមការរីកចំរើន ក្រុមប្រឹក្សាប្រជាជនបដិវត្ត និង គណៈចាត់តាំងមជ្ឈិមបានយល់ព្រមអោយមន្ទីរមាន ២នាយកដ្ឋាន

បានលទ្ធផលក្នុងរយៈពេល ១០ឆ្នាំនេះដូចតទៅ ៖ - ចុះធ្វើទំនាក់ទំនងជាមួយក្រសួង មជ្ឈិម ចំនួន ១.២៣០ លើក ឧទ្ទេសនាមឯកសារទៅខេត្ត-ក្រុង ៣៨លើក ចូលរួមសន្និបាតខេត្ត-ក្រុង ១០២លើក រៀបចំបំពាក់ឥស្សរិយយសជូនជំនាញការវៀតណាមនៅខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ៧លើក នៅក្រសួង ១៧លើក បើកមហាសន្និបាតប្រលងប្រណាំងតាមវេនរាល់ឆ្នាំ និងទូទាំងប្រទេសលើកទី ១ ឆ្នាំ ១៩៨៣ ទទួលគណៈប្រតិភូវៀតណាម ចូលរួមសន្និបាតប្រលងប្រណាំងនៅវៀតណាម ១លើក ចុះធ្វើការងារប្រលងប្រណាំងជាមួយរណសិរ្ស ៧៦៨ វៀតណាម និងស្តាប់របាយការណ៍ក្រសួងការពារប្រទេសពីបញ្ជាការប់ស្ការទីក្រព ចូលរួមពិធីចុះកិច្ចសន្យាប្រលងប្រណាំង តាមដាននយុទ្ធនាការទិញស្បៀងដឹកជញ្ជូនស្បៀង បំផុសចលនាប្រជាជនលក់ស្រូវ ពិនិត្យស្ថានីយ៍តាមមូលដ្ឋាន ទៅធ្វើទស្សនកិច្ចដកពិសោធន៍នៅប្រទេសវៀតណាម និងបូកសរុបលទ្ធផលប្រលងប្រណាំងទូទាំងប្រទេស ១០ឆ្នាំ ។ បានធ្វើលិខិតបទដ្ឋានផ្នែកក្នុងបំរើអោយការងាររបស់ក្រុមប្រឹក្សាប្រលងប្រណាំងមជ្ឈិម ដោះស្រាយការលើកសរសើរជូនរង្វាន់ជាគ្រឿងឥស្សរិយយស ប័ណ្ណសិទ្ធិ នាមវីរៈអង្គភាព វីរៈជន បានផលិតសញ្ញា ៧ មករា ខួបលើកទី ៥ សញ្ញាវីរៈអង្គភាព វីរៈជន សញ្ញាពលករគំរូ សញ្ញាអនុស្សាវរីយ៍ពលកម្មការពារមាតុភូមិ ផលិតទង់ជ័យលាភី សញ្ញាខួបអនុស្សាវរីយ៍លើកទី ១០ ថ្ងៃជ័យជំនះ ៧-១ ព្រះពុទ្ធប័ណ្ណ លិខិតរូបភាព សញ្ញា សៀវភៅ និងឯកសារមួយចំនួន ។ បានចូលរួមប្រជុំការងារ ២៤០ លើក សរសេររបាយការណ៍ និងកំណត់ហេតុ ២៥៣ លេខ ។

នាយកដ្ឋានបានបំរើការងារជូនក្រុមប្រឹក្សាប្រលងប្រណាំងសរសើរជូនរង្វាន់មជ្ឈិម សំរេចបានភារកិច្ចរបស់ខ្លួន មកពីកម្មាភិបាល បុគ្គលិក មានស្មារតីភ្ញាក់រលឹក ថៃប្រឹតខ្ពស់ ក៏ប៉ុន្តែការវាយតំលៃស្នាដៃរបស់បុគ្គល ឬអង្គភាព នៅមានការរំលងខ្លះ មកពីកង្វះខាត កម្មាភិបាល បុគ្គលិក កម្មករ ឯការសរសេរប័ណ្ណក៏យឺតយ៉ាវខ្លះដែរ ។

- <u>ការងារកំណត់ព្រំដែន</u> ៖

ក្នុងឋានៈជាលេខាធិការនៃគណៈកម្មការកំណត់ព្រំដែន និងខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ផ្នែកនេះមានកម្មាភិបាល បុគ្គលិក ៣៤ នាក់ បានធ្វើការប្រជុំនៅវៀតណាម និងកម្ពុជាចំនួន៣៨លើក ធ្វើការបោះបង្គោលព្រំដែនខេត្តស្វាយរៀង ព្រៃវែង កំពង់ចាម ចំនួន ៩២ បង្គោល ប្រវែង ២៣២ គីឡូម៉ែត្រ ។ បានធ្វើការស្រាវជ្រាវទាល់ដែនសមុទ្រ ៣ ខែ កសាងឯកសារប្លង់ទីតាំងបង្គោលចំនួន ២៣ ផ្ទាំង ។ បានប្រមូលឯកសារផែនទីបាន ២ តោន បំពាក់សម្ភារៈបាន ៤០ភាគរយ បានលើកផែនការបណ្តុះបណ្តាលកម្មាភិបាលជំនាញ ដោយបញ្ជូនសិស្សទៅបរទេសបាន ៨រូបហើយ ។

សំរេចបានដូចនេះ មកពីកម្មាភិបាល បុគ្គលិក អនុវត្តការងារមានប្រសិទ្ធភាព ទោះបីលំបាកលត្រានុមិតដូចជាទីតាំងសំបូរដោយគ្រាប់មីនបង្កប់ សម្ភារៈមិនតុល្យភាពក៏ដោយ ក៏សំរេចបានលទ្ធផលការងារ ។ កម្មាភិបាលបានទៅធ្វើទស្សនកិច្ចដកពិសោធន៍ការងារ ២លើក នៅវៀតណាម និង ០១លើក នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ហើយបានទទួលការលើកសរសើរជូនរង្វាន់ពីថ្នាក់ខេត្តចំនួន ៤៦ និង ពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី មួយចំនួន ។ តែការលំបាកនៅមានសេសសល់ដូចជា កម្រិតយល់ដឹងខាងបច្ចេកទេសនៅទាប អ្នកបច្ចេកទេសក៏មានតិច ពិនិត្យ និងអានផែនទីមិនសូវស៊ីជំរៅ គ្មានឯកសារគោលសំរាប់ធ្វើការពិគ្រោះ ផែនទីសំរាប់ផ្ទៀងផ្ទាត់

និងផែនទីមិនត្រូវគ្នា ការដាក់បង្គោលព្រំដែន ខុសបំណាំរបស់ប្រជាជន ធ្វើការកំណត់ទីតាំង និងបោះបង្គោលមួយចំនួនមិនបានត្រឹមត្រូវ សង់ឡើងវិញជាថ្មីច្រើនលើក វត្ថុធាតុគោលលើដី ប្រែប្រួលរូបរាងដើម ដោយសារធម្មជាតិ និងសង្គ្រាមនាំអោយបាត់ពេលវេលាធ្វើការសន្និដ្ឋាន ។

- ការងារគ្រប់គ្រងការទទួល និងបែងចែកជំនួយមនុស្សធម៌ :

ឆ្នាំ ១៩៧៩ - ១៩៨០ ការចែកចាយជំនួយមនុស្សធម៌ដល់ដៃប្រជាជន ជាសម្ភារៈប្រើប្រាស់ស្បៀង ពូជស្រូវ ពូជសត្វ គ្រឿងយន្ត សម្ភារៈសិក្សា .... ត្រូវបានធ្វើផ្ទាល់ តែមិនបានគ្រប់គ្រងហ្មត់ចត់ល្អទេ ។ ពីឆ្នាំ ១៩៨១ ដល់បច្ចុប្បន្នការបែងចែកជំនួយត្រូវបង្វែរមក ធ្វើការគ្រប់គ្រងទូទាត់ជាសាច់ប្រាក់ចូលថវិការដ្ឋវិញ ។ ជំនួយត្រូវថយចុះ ៣ ដងទៅ ឆមាសទី ១ ឆ្នាំ ១៩៨៨នេះ បើប្រៀបធៀបនឹងឆ្នាំ ១៩៨៧ ។ ក្នុងរយៈ ១០ឆ្នាំនេះ ជំនួយសរុបទទួលបាន ៧៧៨.៧២០ តោន ត្រូវជាប្រាក់ ៩៩១.៨៩៦.៦២០៛ ក្នុងនោះទូទាត់បាន ស្រេចតែ ៤៥១.៨៥១.៥៨៧៛ ទេ ។

ការងារនេះមានសកម្មភាពខ្លាំងក្លាពីដើមរហូតមក តែបច្ចុប្បន្នជំនួយត្រូវចុះថយខ្លះ ដោយទៅតាមការរីកចំរើនរបស់ប្រទេសជាតិ តែយើងខិតខំអូសទាញ និងសុំជំនួយពីអង្គការអន្តរជាតិអោយបានច្រើនថែមទៀត ។ ធ្វើបានដូច្នេះមកពីកម្មាភិបាល បុគ្គលិក កម្មករ មានកំរិតសមត្ថភាពរ៉ាប់រងការងារនេះបានល្អ និងសណ្ដាប់ធ្នាប់ ។

ឃ - សេចក្ដីសន្និដ្ឋាន :

ឆ្នាំ ១៩៨៨ ជាឆ្នាំគន្លឹះនៃការអនុវត្តកម្មវិធីសេដ្ឋកិច្ច ៥ ឆ្នាំលើកទី ១ និងជាឆ្នាំដែលយើងប្រារព្ធខួបលើកទី ១០ នៃថ្ងៃជ័យជំនះ ៧មករា ។ រយៈ ១០ឆ្នាំកន្លងមកនេះ ខុទ្ទកាល័យ-ក្រុមប្រឹក្សារដ្ឋមន្ត្រី បានសំរេចលទ្ធផលជាច្រើន ក្នុងការពុះពារអនុវត្តភារកិច្ចរបស់ខ្លួន គឺផ្ដើមចេញពីការ " ធ្វើជួយសព្វគ្រប់ " របស់សមមិត្តជំនាញការវៀតណាម មកធ្វើម្ចាស់ស្វ័យរ៉ាប់រងការងារដោយខ្លួនឯង ជំនួយការនិងបំរើក្រុមប្រឹក្សារដ្ឋមន្ត្រី លើគ្រប់ការងាររបស់ខុទ្ទកាល័យ-ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលជាមោទនភាពដ៏ក្រៃលែងរបស់យើងមិនអាចបំភ្លេចបាន ។ លទ្ធផលរីកចំរើនដែលទទួលបានមកពី :-

- គណៈកម្មាធិការបក្សភាគមូលដ្ឋានខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី គណៈកម្មាធិការ ស-ក្រុមស្នូល និង អង្គការមហាជន បានសហការជាមួយថ្នាក់ដឹកនាំខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ដឹកនាំមហាជន កម្មាភិបាល បុគ្គលិក កម្មករ បំពេញការងារបានល្អ អនុវត្តគោលមាគ៌ា-នយោបាយរបស់បក្សនិងរដ្ឋ ពិសេសពង្រីកបាននិងកសាងបាន ចំនួនកម្លាំងពិតបដិវត្តយ៉ាងច្រើន និងរឹងមាំ ។ បក្សជន ក្រុមស្នូល សម្ព័ន្ធយុវជន អង្គការមហាជន បានចុះធ្វើគំរូមហាជនធ្វើអោយសន្ទុះរីកចំរើនធានា ធ្វើម្ចាស់លើការងារដឹកនាំ ដែលនាំការងារបានល្អគួរសង្ឃឹម ។

- កម្មាភិបាល ដឹកនាំតាមមុខជំនាញឯកទេសក្នុងខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី បានយក-

-:- ពិចារណាស្រាវជ្រាវ និង លើកយោបល់លើវិធានការកែលំអខាងការគ្រប់គ្រងខាងសេដ្ឋកិច្ច សង្គមកិច្ច អោយបានសមស្របជាជំហ៊ាន ៗ ។

-:- ជំរុញអោយបានលទ្ធផលជាក់ស្តែងការងារតំកល់ឯកសារ ជំនាញការ ព្រំដែន... ។

ខាងលើនេះគឺជាការងារសំខាន់ ៗ មួយចំនួនដែលខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី សំរេចបានរយៈ ១០ ឆ្នាំកន្លងមក ស្តែងអោយឃើញថា សមិទ្ធផលបដិវត្តន៍ដែលយើងសំរេចបាននោះ ធ្វើអោយកម្មាភិបាល បុគ្គលិក កម្មករ នៃខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីមានមោទនភាពខ្ពស់ មានជំនឿជឿជាក់លើការដឹកនាំរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា មានទស្សនៈពឹងផ្អែកលើកំលាំងខ្លួនជាសំខាន់ ប្រើប្រាស់អោយអស់លទ្ធភាពកំលាំងទុន សំភារៈ កំលាំងប្រាជ្ញា កំលាំងមនុស្ស ដើម្បីជំរុញការងារ និងអភិវឌ្ឍន៍មាតុភូមិកម្ពុជារបស់ខ្លួនបានជឿនលឿន រីកចំរើនលើគ្រប់វិស័យយ៉ាងឆាប់រហ័ស ។

រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

គង់ - សំអុល

កន្លែងទទួល :

- ខុទ្ទកាល័យមជ្ឈិមបក្ស
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
- គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី
  « ដើម្បីជូនជ្រាបជារបាយការណ៍ »
- គ្រប់នាយកដ្ឋាន អង្គភាពចំណុះខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
  « ដើម្បីអនុវត្តតាមទិសដៅការងារ »
- ឯកសារ - កាលប្បវត្តិ